UNDP
Empowered lives.
Resilient nations.

# ព្រឹត្តិបត្រព័ត៌មាន

លេខ ៤៤
ខែ ធ្នូ ឆ្នាំ ២០១៤

*យូអិនឌីភី ធ្វើដៃគូជាមួយប្រជាជនគ្រប់ស្រទាប់សង្គមក្នុងការជួយប្រជាជាតិឲ្យមានភាពស្ថិតស្ថាញទប់ទល់នឹងវិបត្តិ ជំរុញ និងរក្សាចីរភាពកំណើន សំដៅលើកស្ទួយគុណភាពនៃជីវភាពសម្រាប់ទាំងអស់គ្នា។ យើងមានវត្តមានក្នុងប្រទេសនិងដែនដីជាង ១៧០ ហើយយើងប្រើប្រាស់ទស្សនវិស័យសកល និងក្នុងស្រុក ដើម្បីជួយប្រជាជន និងប្រជាជាតិកសាងជីវភាពឲ្យបានកាន់តែប្រសើរ និងរឹងមាំថែមទៀត។*

## វិទ្យុផ្សាយសម្លេងដោយជនពិការ និងដើម្បីជនពិការ

**ភ្នំពេញ** - "សូមស្វាគមន៍ពីកម្មវិធីយល់ដឹងសកលរបស់យើង ដែលជាកម្មវិធីផ្សាយមួយរបស់វិទ្យុសម្លេងជនពិការផ្សាយចេញពីរាជធានីភ្នំពេញទៅកាន់ខេត្តសៀមរាប FM92.25 MHz និងខេត្តព្រះសីហនុ FM88.75 MHz"។

ពីក្នុងបន្ទប់ស្ទូឌីយ៉ូតូចចង្អៀតនៅក្នុងបរិវេណវត្តថាន់ សម្លេងរបស់នាង កុំ លក្ខិណា គឺជាការប្រកាសការចាប់ផ្តើមផ្សាយជាលើកដំបូងនូវកម្មវិធីវិទ្យុផ្សាយសម្លេងដោយជនពិការ និងដើម្បីជនពិការ Voice of Persons with Disabilities/VPD។ បេសកកម្មរបស់វា គឺផ្តល់ច្រកតាមរលកធាតុអាកាសមួយ សម្រាប់ឲ្យជនពិការបញ្ចេញសម្លេងរបស់ពួកគេដោយផ្ទាល់ ក៏ដូចជាដើម្បីលើកកំពស់សិទ្ធិ និងឱកាសរបស់ខ្លួនជាសមាជិកស្មើភាពគ្នានៅក្នុងសង្គមកម្ពុជា។

នាង កុំ លក្ខិណា និយាយថា "នៅប្រទេសកម្ពុជា យើងៗមានវិទ្យុជាច្រើន ប៉ុន្តែវិទ្យុទាំងអស់នោះ ផ្សព្វផ្សាយ

*តទៅទំព័រទី ២*




Photo: UNDP Cambodia

*នាង កុំ លក្ខិណា ជនពិការ ធ្វើការប្រកាសផ្សាយជាលើកដំបូងនៃវិទ្យុសម្លេងជនពិការ ពីក្នុងស្ទូឌីយ៉ូដែលមានទីតាំងក្នុងវត្តថាន់ កាលពីថ្ងៃ ១៨ វិច្ឆិកា ២០១៤។*

## កសិកម្មចម្រុះជួយធ្វើឲ្យជីវភាពអ្នកភូមិធម្មជាតិប្រសើរជាងមុន



Photo: UNDP Cambodia

*កសិករឈ្មោះ រុន ម៉ាច កំពុងបេះសណ្តែកគួរក្នុងចម្ការក្រោយផ្ទះរបស់គាត់នៅក្នុងភូមិធម្មជាតិ ខេត្តព្រះវិហារ។*

**ខេត្តព្រះវិហារ** - កំដៅថ្ងៃក្តៅហែង ប៉ុន្តែអ្នកស្រី រួន ម៉ាច នៅតែបន្តធ្វើការក្នុងច្បារបន្លែ ដោយពាក់មួកហាមធំ ដើម្បីការពារផ្ទៃមុខពីកំដៅព្រះអាទិត្យ។

ស្ត្រីអាយុ ៤៨ឆ្នាំ ម្នាក់នេះបានពោលថា "កាលពីមុនខ្ញុំធ្លាប់ស៊ីឈ្នួលច្រូតស្រូវឲ្យគេ តែរកមិនបានប៉ុន្មានទេព្រោះអីការងារនឹងមានតែមួយភ្លែតៗតែផុតរដូវប្រមូលផលស្រូវវាអស់ដែរហើយមានស្អីរកលុយទៀត"។

ការរស់នៅរបស់គាត់បានប្រសើរឡើងក្រោយពីគាត់បានចាប់ផ្តើមដាំបន្លែនៅជុំវិញផ្ទះដែលស្ថិតនៅក្នុងភូមិធម្មជាតិនៅខេត្តព្រះវិហារកាលពីប្រមាណមួយឆ្នាំកន្លងមកនេះ។

*តទៅទំព័រទី ៤*

## ស៊ុយអែដបន្តផ្តល់ហិរញ្ញវត្ថុសម្រាប់កម្មវិធីប្រែប្រួលអាកាសធាតុនៅកម្ពុជា




Photo: UNDP Cambodia

*លោកស្រី Anna Maj Hultgård ឯកអគ្គរដ្ឋទូតស៊ុយអែដ និងលោកស្រី Setsuko Yamazaki នាយកយូអិនឌីភី ប្រចាំនៅកម្ពុជា កាលពីថ្ងៃទី១៤ វិច្ឆិកា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជំនួយថ្មីរបស់ស៊ុយអែដ សម្រាប់កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ដំណាក់កាលទីពីរ។*

**ភ្នំពេញ** - ប្រទេសស៊ុយអែដ បានផ្តល់ជំនួយ ២៨.០០០.០០០ ក្រូណា (ប្រមាណជា ៣,៨លាន ដុល្លាអាមេរិក) ដល់កិច្ចផ្តួចផ្តើមមួយដែលអនុវត្តដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (យូអិនឌីភី) សំដៅជួយកម្ពុជា បង្កើនសមត្ថភាពដើម្បីឆ្លើយតបនឹងផលប៉ះពាល់ការប្រែប្រួលអាកាសធាតុមកលើការអភិវឌ្ឍរបស់ខ្លួន។

*តទៅទំព័រទី ៦*

# វិទ្យុផ្សាយសម្លេងដោយជនពិការ...

តពីទំព័រទី ១

ជាលក្ខណៈទូទៅ។ រីឯយើងដែលជាអង្គការជនពិការកម្ពុជាក្នុងការបង្កើត "វិទ្យុសម្លេងជនពិការ" នេះយើងមិនរើសអើងរវាងជនពិការនិងជនមិនពិការទេ តែដោយឡែកយើងធ្វើការផ្តោតលើការផ្តល់ឱកាសឲ្យជនពិការដើម្បីឲ្យគាត់អាចបញ្ចេញនូវសម្លេងនិងអារម្មណ៍របស់គាត់ក្នុងវិទ្យុនោះផងដែរ"។

ជនពិការនៅកម្ពុជាមានចំនួនប្រមាណ ៧០០.០០០ នាក់ ឬ ត្រូវជា ៥% នៃចំនួនប្រជាជនកម្ពុជាសរុប។ ពួកគេប្រឈមនឹងឧបសគ្គជាច្រើនក្នុងជីវិតរបស់ខ្លួនដែលរារាំងពួកគេពីការអនុវត្តសិទ្ធិស្មើគ្នាឲ្យបានពេញលេញ និងការបញ្ចេញសក្តានុពលរបស់ខ្លួនដូចពលរដ្ឋដទៃទៀតក្នុងសង្គម។ ការផ្សាយវិទ្យុសម្លេងជនពិការមានគោលដៅ កែតម្រូវឥរិយាបថសង្គមកុំឲ្យចាត់ទុកជនពិការថាជាបន្ទុក ប៉ុន្តែគឺជាធនធានមានតម្លៃរួមចំណែកក្នុងការអភិវឌ្ឍប្រទេស។

វិទ្យុនេះគឺជាសមាសភាគមួយនៅក្រោមកិច្ចផ្តួចផ្តើមសិទ្ធិជនពិការកម្ពុជា (Disability Rights Initiative Cambodia/DRIC) ដែលបានទទួលមូលនិធិពីក្រសួងការបរទេស និងពាណិជ្ជកម្ម (DFAT) នៃប្រទេសអូស្ត្រាលី។ មូលនិធិ Abilis Foundation នៅប្រទេសហ្វាំងឡង់ក៏បានផ្តល់ថវិកា និងសម្ភារៈសម្រាប់បង្កើតវិទ្យុនេះឡើង។ វិទ្យុនេះត្រូវបានបង្កើតឡើងនៅខែសីហា និងមានស្នាក់ការនៅការិយាល័យនៃអង្គការជនពិការកម្ពុជា (CDPO) ក្នុងវត្តថាន់។ ចាប់ពីពេលនោះមកស្ថានីយ៍នេះបានធ្វើការយ៉ាងសកម្មដើម្បីបង្កើតក្រុមអ្នកផ្សាយរបស់ខ្លួន។ នៅថ្ងៃទី ១៨ ខែវិច្ឆិកា ស្ថានីយ៍នេះបានចាប់ផ្តើមការផ្សាយជាលើកដំបូងនូវកម្មវិធីនានាដែលបុគ្គលិកនៃស្ថានីយ៍នេះបានរៀបចំឡើងដោយខ្លួនឯង។ ក្រៅពីកម្មវិធី "យល់ដឹងសកល" នៅមានកម្មវិធីមួយទៀតឈ្មោះថា "សម្លេងខ្ញុំ សិទ្ធិខ្ញុំ" ដែលជាកម្មវិធីពិភាក្សាតុមូលចេញផ្សាយម្តងក្នុងមួយសប្តាហ៍។

នាង កុំ លក្ខិណា អាយុ២៦ឆ្នាំ និងជាជនពិការផងដែរនោះ គឺជាបុគ្គលិកម្នាក់នៅក្នុងក្រុមអ្នកផ្សាយនេះ។ គាត់ចាត់ចែងកម្មវិធី "យល់ដឹងសកល" ដែលជាកម្មវិធីទទួលទូរស័ព្ទហៅចូល និងដែលផ្សាយបួនម៉ោងក្នុងមួយសប្តាហ៍។ គាត់មានសហការីផ្សាយព័ត៌មានម្នាក់ជាបុរសឈ្មោះ ស្រ៊ុន ចាន់នី ដែលមានអាយុ ២៧ឆ្នាំ។

លោក ស្រ៊ុន ចាន់នីពោលថា "ខ្ញុំមិនមែនជាជនពិការឡើយ ប៉ុន្តែខ្ញុំចង់លើកកំពស់សិទ្ធិជនពិការ។ ធ្វើការក្នុងស្ថានីយ៍វិទ្យុនេះ អាចឲ្យខ្ញុំយល់ពីបញ្ហាពិការភាពបានប្រសើរជាងមុន និងជួយជនពិការឲ្យបណ្តុះគំនិត ជាវិជ្ជមានសម្រាប់អនាគតខ្លួនឯងទៅថ្ងៃមុខ"។

បន្ទាប់ពីបានទទួលការបណ្តុះបណ្តាលខ្លះៗ ជាមូលដ្ឋាន អំពីការផ្សាយវិទ្យុថ្ងៃដំបូងរបស់អ្នកទាំងពីរនេះនៅក្នុងការងារនេះ ពុំសូវជាមានភាពរលូនឡើយ។ លោក ស្រ៊ុន ចាន់នី ទទួលស្គាល់ថា គាត់មានអារម្មណ៍ភ័យបន្តិចដែលធ្វើឲ្យគាត់និយាយរដាក់រដុបក្នុងពេលកំពុងផ្សាយតាមរលកអាកាស។ ប្រការនេះបានតម្រូវឲ្យការីបញ្ជាសម្លេងដែលស្ថិតនៅម្ខាងនៃបង្អួចកញ្ចក់បញ្ឈប់ការផ្សាយដោយចាក់បទចម្រៀងខ្មែរជាជំនួសវិញ។

នាង ជុំ រដ្ឋា ដែលជាអ្នកបញ្ជាឧបករណ៍សម្លេងបានឲ្យយោបល់ទៅលោក ស្រ៊ុន ចាន់នី "បន្ធូរអារម្មណ៍កុំព្យាយាមធ្វើដូចអានសុន្ទរកថា" ហើយលោក ស្រ៊ុន ចាន់នីក៏ងក់ក្បាលឆ្លើយតបវិញជាមួយនឹងការញញឹម។

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាសិទ្ធិជនពិការ (CRPD) នៅឆ្នាំ ២០១២ ដែលអះអាងអំពីការប្តេជ្ញារបស់ខ្លួន ក្នុងការកែលម្អការរស់នៅរបស់ជនពិការ។ រដ្ឋាភិបាលក៏បានអនុម័តច្បាប់ និងផែនការយុទ្ធសាស្ត្រមួយចំនួនស្តីពីពិការភាពផងដែរនៅក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ។

កញ្ញា កុំ លក្ខិណា ពោលថា ទោះជាយ៉ាងណាក៏ដោយ ការរើសអើងចំពោះជនពិការនៅតែមាននៅឡើយពាក់ព័ន្ធនឹងឥរិយាបថសង្គមមកលើជនពិការ កង្វះឱកាសការងារ និងការលំបាកក្នុងការចេញចូល និងប្រើប្រាស់ទីកន្លែង និងអគារមួយចំនួន។

កញ្ញាពោលថា "សេចក្តីសង្ឃឹមរបស់ខ្ញុំគឺចង់ឲ្យវិទ្យុនេះដំណើរការបានល្អ និងមានប្រសិទ្ធភាពក្នុងការកែលម្អការយល់ឃើញរបស់សារធារណជនជាទូទៅអំពីពិការភាព។ ការរួមបញ្ចូលជនពិការក្នុងការអភិវឌ្ឍ គឺជាប្រការសំខាន់ខ្លាំងណាស់។ ពួកគេពិការអាចពិការខ្លួនមែន ប៉ុន្តែគំនិត ស្មារតី និងបញ្ញារបស់ពួកគេមិនពិការទេ"។

កម្មវិធី DRIC អនុវត្តរួមគ្នាដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP), អង្គការសុខភាពពិភពលោក (WHO) និងមូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF)។

ដើម្បីស្វែងយល់បន្ថែមទៀតអំពីកម្មវិធីនេះ សូមចុច៖ *http://www.kh.undp.org/content/cambodia/en/home/operations/projects/democratic_governance/disability-rights-initiative-cambodia.html*



PHOTO: UNDP Cambodia

*រូបកណ្តាល នាង ជុំ រដ្ឋា កំពុងធ្វើការណែនាំបង្ហាញដល់នាង កុំ លក្ខិណា និងលោក ស្រ៊ុន ចាន់នី អំពីរបៀបធ្វើការឆ្លើយឆ្លងជាមួយអ្នកស្តាប់វិទ្យុសម្លេងជនពិការ ដែលបានចាប់ផ្តើមការផ្សាយជាលើកដំបូងកាលពីថ្ងៃ ១៨ វិច្ឆិកា ២០១៤។*

# ជម្រុញកិច្ចគាំពារសង្គមក្នុងបញ្ហាមេរោគអេដស៍ គឺជាការវិនិយោគដ៏ល្អលើមូលធនមនុស្ស

**ភ្នំពេញ** - ការបង្កើនប្រសិទ្ធភាពនៃយន្តការគាំពារសង្គមដែលមានស្រាប់ និងយន្តការដែលលេចឡើងថ្មី មានសារៈសំខាន់ណាស់ក្នុងការជួយពលរដ្ឋដែលមានផ្ទុកមេរោគអេដស៍ (PLHIV) និងក្រុមជនរងការប៉ះពាល់សំខាន់ៗក្នុងការដឹកនាំខ្សែជីវិតប្រកបដោយសុខភាពល្អ និងផលិតភាព។ នេះក៏ជាការវិនិយោគដ៏ល្អមួយផងដែរលើមូលធនមនុស្សសំដៅរួមវិភាគទានដល់ការអភិវឌ្ឍដោយចីរភាពនិងសមធម៌នៅកម្ពុជា។



Photo: UNDP Cambodia

*អ្នកចូលរួមសិក្ខាសាលាកំពុងអានរបាយការណ៍ស្តីពីផលប៉ះពាល់សេដ្ឋកិច្ចសង្គមនៃមេរោគហ៊ីវ និងជំងឺអេដស៍ នៅប្រទេសកម្ពុជា។*

ទាំងនេះគឺជាសារគន្លឹះដែលបានលើកឡើងនៅក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី ការជម្រុញកិច្ចគាំពារសង្គមក្នុងបញ្ហាមេរោគអេដស៍ ដែលបានរៀបចំឡើងរួមគ្នាដោយ UNDP និង UNAIDS កាលពីថ្ងៃទី ២ ខែតុលា ក្រោមភាពជាដៃគូជាមួយបណ្តាញពលរដ្ឋដែលមានផ្ទុកមេរោគអេដស៍កម្ពុជា។ នៅក្នុងពិធីនេះមានអ្នកចូលរួមច្រើនជាង ៧០នាក់ ដែលជាតំណាងមកពីរាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងក្រុមសហគមន៍ ដែលរួមទាំងបុគ្គលិកបម្រើការកំសាន្ត បុរសស្រឡាញ់បុរស ក្រុមស្រីស្រស់ និងអ្នកប្រើគ្រឿងញៀនផងដែរ។

លោក ណាប៉ូឡេអុង ណាវ៉ារ៉ូ នាយករង UNDP ប្រចាំនៅកម្ពុជា មានប្រសាសន៍ថា "កិច្ចគាំពារសង្គមដែលគិតគូរអំពីបញ្ហាមេរោគអេដស៍ គឺជាបញ្ហាសមធម៌ និងក៏ជាការវិនិយោគដ៏ល្អមួយដែលផ្តល់ចំណូលខ្ពស់ផងដែរ"។ លោកបានបន្ថែមថា "កិច្ចការនេះនៅតែជាផ្នែកថ្មីមួយនៅអាស៊ី និងតំបន់ដ៏ទៃទៀត ហើយការជួបប្រជុំនេះបង្ហាញថា កម្ពុជាក្លាយជាអ្នកឈានមុខម្តងទៀតលើកិច្ចការអភិវឌ្ឍន៍សកលមួយនេះ"។

ទោះបីជាមានវឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រ និងកំណែលម្អលើការព្យាបាលអ្នកផ្ទុកមេរោគអេដស៍ហើយក៏ដោយ ក្រុមអ្នកផ្ទុកមេរោគអេដស៍ និងក្រុមអ្នករងការប៉ះពាល់សំខាន់ៗ នៅតែប្រឈមចំពោះការលំបាកខាងសង្គមកិច្ច និងសេដ្ឋកិច្ចក្នុងអត្រាវិសមាមាត្រនៅឡើយ និងងាយធ្លាក់ចុះមកក្រោមខ្សែបន្ទាត់ក្រីក្រវិញ។

តាមរយៈការប្រើប្រាស់ភស្តុតាងពីការសិក្សាថ្មីៗ លោក ស៊ិន សុជារិទ្ធ មន្ត្រីជាតិសម្របសម្រួលបណ្តាញក្រុមអ្នកផ្ទុកមេរោគអេដស៍ បានពោលថា ក្នុងស្ថានភាពដែលរស់នៅជាប់នឹងខ្សែបន្ទាត់នៃភាពក្រីក្រ ក្រុមអ្នកផ្ទុកមេរោគអេដស៍ និងក្រុមអ្នករងការប៉ះពាល់សំខាន់ៗ ទំនងជាមិនបានរាប់បញ្ចូលនៅក្នុងអត្តសញ្ញាណកម្មជនក្រីក្រ និងប្រព័ន្ធគាំពារសង្គមឡើយ។ ហេតុផលចំបងមួយគឺ ពួកគេទំនងជាងាយផ្លាស់ទី ដូច្នេះអាចមិនបានរាប់បញ្ចូលនៅក្នុងការវាយតម្លៃអត្តសញ្ញាណកម្មជនក្រីក្រដែលបានធ្វើឡើងនៅតាមគ្រួសារ។ លោក ស៊ិន សុជារិទ្ធ ក៏បានពោលផងដែរថា ក្រុមអ្នកផ្ទុកមេរោគអេដស៍ និងជនរងគ្រោះជាច្រើន មិនបានមករកសេវានានាឡើយ ដោយសារពួកគេប្រឈមការស្អប់ខ្ពើម និងការរើសអើង ឬពួកគេព្រួយបារម្ភថា អ្នកណាម្នាក់អាចបើកចំហអំពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ពួកគេ។ អ្នកដទៃអាចមិនដឹងអំពីវត្តមានសេវាទាំងនេះ ឬមិនដឹងរបៀបទទួលបានសេវាទាំងនេះទៀតផង។

ឯកឧត្តម អៀង ម៉ូលី ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍ បានសង្កត់ធ្ងន់ថា "ការស្វែងយល់ និងការគិតគូរអំពីតម្រូវការពិសេស និងកាលៈទេសៈដែលក្រុមអ្នកផ្ទុកមេរោគអេដស៍ ក្រុមអ្នករងការប៉ះពាល់សំខាន់ៗ និងក្រុមគ្រួសាររបស់ពួកគេបានប្រឈម និងការគោរពសិទ្ធិរបស់ពួកគេមានសារៈសំខាន់ខ្លាំងណាស់"។ ឯកឧត្តមក៏បានអះអាងផងដែរថារដ្ឋាភិបាលកំពុងបង្កើនការទទួលខុសត្រូវកាន់តែច្រើនឡើង និងធ្វើការវិនិយោគធនធានក្នុងស្រុក លើការឆ្លើយតបនឹងមេរោគអេដស៍-ជំងឺអេដស៍ នៅពេលដែលមូលនិធិពីប្រភពខាងក្រៅថយចុះ។

ឯកឧត្តម ងី ច័ន្ទផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARD) មានប្រសាសន៍ថា គេគួរតែមានការពិនិត្យមើលឱកាសថ្មីៗ ដើម្បីកែលម្អលទ្ធភាពទទួលបានសេវាគាំពារសង្គមសម្រាប់ក្រុមអ្នកផ្ទុកមេរោគអេដស៍ និងក្រុមអ្នករងការប៉ះពាល់សំខាន់ៗ។ ឯកឧត្តមបានកត់សំគាល់ថា កិច្ចប្រឹងប្រែងនានាកំពុងតែអនុវត្ត ដើម្បីបង្កើតយន្តការថ្មីសម្រាប់កំណត់អត្តសញ្ញាណជនក្រីក្រនៅតាមទីប្រជុំជន និងធ្វើការកែសម្រួលមូលនិធិសមធម៌សុខភាព ដើម្បីឆ្លើយតបឲ្យកាន់តែមានប្រសិទ្ធភាពតាមតម្រូវការរបស់ក្រុមអ្នកផ្ទុកមេរោគអេដស៍។ ឯកឧត្តមមានប្រសាសន៍ថា កិច្ចប្រឹងប្រែងនានាទាមទារឲ្យមានវិធាននៃការសម្របសម្រួលពហុវិស័យឲ្យបានល្អដែលពាក់ព័ន្ធជាមួយក្រសួង និងអាជ្ញាធរពាក់ព័ន្ធនានានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយការចូលរួមរបស់ក្រុមសហគមន៍នៅគ្រប់ដំណាក់កាលនៃដំណើរការនេះក៏មានសារៈសំខាន់ណាស់ដែរ។

សិក្ខាសាលានេះមានវាគ្មិនមកពីឥណ្ឌា ដែលជាអ្នកដឹកនាំពិភពលោកលើកិច្ចគាំពារសង្គមដោយគិតគូរអំពីបញ្ហាមេរោគអេដស៍។ ដោយមានប្រជាជនច្រើនជាងពីរលាននាក់ផ្ទុកមេរោគអេដស៍ ការរួមបញ្ចូលបញ្ហាមេរោគអេដស៍ទៅក្នុងសេវាគាំពារសង្គម បានក្លាយជាផ្នែកសំខាន់មួយនៃការឆ្លើយតបនឹងជំងឺអេដស៍នៅឥណ្ឌា។ ការរៀនសូត្រពីដៃគូត្បូង-ត្បូងមានសារៈសំខាន់ណាស់នៅពេលដែលកម្ពុជាជម្រុញកិច្ចការដ៏មានសារៈសំខាន់នេះ។

## សម្ពោធការវាយតម្លៃយេនឌ័រនៅកម្ពុជា ឆ្នាំ ២០១៤

ការវាយតម្លៃយេនឌ័រនៅកម្ពុជា (CGA) ឆ្នាំ ២០១៤ ក្រោមចំណងជើងថា "ឆ្ពោះទៅរកសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី" ត្រូវបានក្រសួងកិច្ចការនារីសម្ពោធកាលពីថ្ងៃទី១៧ ខែធ្នូ ទន្ទឹមនឹងការប្រកាសផែនការយុទ្ធសាស្ត្រប្រាំឆ្នាំលើកទីបួនដើម្បីសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី ពោលគឺ នារីរតនៈទី៤។

ក្រសួងកិច្ចការនារីបានចេញជាបន្តបន្ទាប់នូវរបាយការណ៍វាយតម្លៃយេនឌ័រនៅកម្ពុជានៅក្នុងទសវត្សរ៍កន្លងទៅ (នៅឆ្នាំ ២០០៤, ២០០៨ និង ២០១៤) ដែលផ្តល់នូវទិដ្ឋភាពរួមពេញលេញមួយអំពីយេនឌ័រនៅក្នុងគ្រប់វិស័យទាំងអស់ តាមរយៈភាពជាដៃគូ និងកិច្ចសហការរួមគ្នារវាងក្រសួងកិច្ចការនារី អង្គការសង្គមស៊ីវិល និងតាមរយៈយន្តការក្រុមការងារបច្ចេកទេសយេនឌ័រ។

ការវាយតម្លៃយេនឌ័រឆ្នាំ ២០១៤ និងផែនការយុទ្ធសាស្ត្រ (នារីរតនៈ ទី៤) ត្រូវបានក្រសួងកិច្ចការនារីរៀបចំឡើង ដោយមានកិច្ចគាំទ្រជិតស្និទ្ធពីកម្មវិធីភាពជាដៃគូរបស់ UNDP ដើម្បីសមភាពយេនឌ័រដែលបានទទួលមូលនិធិគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) ដើម្បីផ្តល់ជាកញ្ចប់គោលនយោបាយរួមដែលផ្អែកលើភស្តុតាងសម្រាប់រួមចំណែកក្នុងការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការរបស់ស្ត្រីកម្ពុជា។

## បញ្ឈប់អំពើហិង្សាមកលើស្ត្រី

នៅក្នុងការប្រារព្ធទិវាអន្តរជាតិដើម្បីលុបបំបាត់អំពើហិង្សាមកលើស្ត្រី កាលពីថ្ងៃទី ២៥ ខែវិច្ឆិកា លោកស្រី ហេឡិន ក្លាក អភិបាល UNDP បានចេញសេចក្តីថ្លែងការណ៍មួយដែលអំពាវនាវឲ្យបន្តការប្តេជ្ញាលុបបំបាត់គ្រប់ទម្រង់នៃអំពើហិង្សាមកលើស្ត្រី និងធានាឲ្យមានយុត្តិធម៌ និងការឧបត្ថម្ភគាំទ្រដល់ជនរងគ្រោះដោយអំពើហិង្សា។

នៅក្នុងសេចក្តីថ្លែងការណ៍នោះលោកស្រី ហេឡិន ក្លាក និយាយថា "ការងាររបស់យើងដើម្បី លុបបំបាត់អំពើហិង្សាមកលើស្ត្រីគឺជាស្នូលនៃការប្តេជ្ញារបស់យើងដើម្បីលើកកំពស់សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី ដែលទាំងពីរនេះគឺជាផ្នែករួមមួយនៃការអភិវឌ្ឍដោយចីរភាព"។

លោកស្រីបន្ថែមថា "ការលុបបំបាត់អំពើហិង្សាមកលើស្ត្រីទាមទារឲ្យមានការកែប្រែឥរិយាបថទាំងនោះនិងនិយាមសង្គមដែលមិនឲ្យតម្លៃចំពោះសិទ្ធិ និងឱកាសរបស់ស្ត្រី។ ការងារនេះទាមទារឲ្យមានការធានាដើម្បីឲ្យស្ត្រីបានចូលរួមស្មើគ្នានៅក្នុងការធ្វើសេចក្តីសម្រេចនៅគ្រប់លំដាប់ថ្នាក់ពីកម្រិតគ្រួសារ រហូតដល់ស្ថាប័នរដ្ឋាភិបាល"។

យោងតាមអង្គការសុខភាពពិភពលោក អំពើហិង្សាមកលើស្ត្រីបានសម្លាប់ស្ត្រីជាច្រើននៅអាយុរវាង១៥ឆ្នាំ និង ៤៤ឆ្នាំ តាមអត្រាដូចរោគមហារីកដែរ។ បន្ទុកនេះមកលើស្ត្រីមានកម្រិតខ្ពស់ជាងការបាត់បង់ជីវិតដោយសារគ្រោះថ្នាក់ចរាចររួមនឹងជំងឺគ្រុនចាញ់ទៅទៀត។ ជនរងគ្រោះដោយសារអំពើហិង្សាមកលើស្ត្រីនៅទូទាំងពិភពលោកក៏មានទាំងកុមារីដែលត្រូវបានបង្ខំឲ្យរៀបការទាំងពីនៅវ័យក្មេង ក៏ដូចជា កុមារី និងស្ត្រីប្រមាណ ១០០ ទៅ ១៤០លាននាក់ដែលបានឆ្លងកាត់ការកាត់ប្រដាប់ភេទផងដែរ។

លោកស្រីក្លាក ពោលថា "អំពើហិង្សាមកលើស្ត្រីជាអំពើដែលមិនអាចទទួលយកបានសោះឡើយ។ នេះជាអំពើរំលោភសិទ្ធិមនុស្សរបស់ស្ត្រី ហើយដែលជនល្មើសត្រូវតែទទួលខុសត្រូវជាចាំបាច់"។

# កសិកម្មចម្រុះជួយធ្វើឲ្យជីវភាពអ្នកភូមិ...

តពីទំព័រទី ១



PHOTO: UNDP Cambodia

*កសិករ រុន ម៉ាច រស់នៅភូមិធម្មជាតិ ខេត្តព្រះវិហារ និយាយថា “ខ្ញុំនឹងប្រឹងធ្វើការដាំបន្លែឲ្យបានកាន់តែច្រើន មិនមែនដើម្បីតម្រូវចិត្តអ្នកណាទេ តែគឺដើម្បីខ្លួនខ្ញុំរកលុយឲ្យបានច្រើនជាងនេះ”។*

គាត់រកប្រាក់ចំណូលជាមធ្យម ២០.០០០រៀល (៥ដុល្លាអាមេរិក) ក្នុងមួយថ្ងៃ ពីការលក់បន្លែរបស់គាត់នៅក្នុងទីផ្សារមួយនៅក្នុងមូលដ្ឋានដែលគាត់រស់នៅ។

សម្រាប់គាត់ និងអ្នកភូមិនៅក្នុងសហគមន៍ដាច់ស្រយាលមួយនេះនៅភាគឧត្តរនៃប្រទេសកម្ពុជា ការប្រែប្រួលប្រសើរឡើងនេះប្រហែលជាពិបាកនឹងកើតមានណាស់ ប្រសិនបើពុំមានម៉ាស៊ីនបូមទឹកដែលដើរដោយថាមពលព្រះអាទិត្យ។ មធ្យោបាយនេះបានដោះស្រាយបញ្ហាខ្វះទឹកពុំរ៉ៃ ដែលពួកគេបានជបប្រទះកន្លងមក។ គម្រោងមួយដែលគាំទ្រដោយ UNDP តាមរយៈជំនួយមូលនិធិពីប្រទេសកាណាដា បានផ្ដល់សេវាកម្មទឹកនេះ។ បន្ថែមលើសេវាកម្មនេះ គម្រោងក៏បានបណ្ដុះបណ្ដាលអ្នកភូមិអំពីបច្ចេកទេសបង្កើនមុខដំណាំដើម្បីបង្កើនសន្តិសុខស្បៀង ប្រាក់ចំណូល និងភាពធន់ចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

កម្ពុជាត្រូវបានគេស្គាល់ជាទូទៅថាស្ថិតក្នុងចំណោមប្រទេសដែលងាយរងគ្រោះបំផុតដោយសារការគំរាមកំហែងនេះ។ នេះដោយសារប្រទេសកម្ពុជាមានប្រជាជនមួយចំនួនធំដលែពឹងផ្អកែលីកសិកម្មអាស្រ័យលីទឹកភ្លៀងសម្រាប់ចិញ្ចឹមគ្រួសារ និងមានសមត្ថភាពទន់ខ្សោយក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

លោកស្រី រួន ម៉ាច ដែលមានកូនពីរនាក់ បានពន្យល់អំពីវិធីដែលគាត់ធ្លាប់បានប្រឹងប្រែងដើម្បីរក្សាច្បារបន្លែរបស់គាត់ឲ្យនៅបៃតងជានិច្ច ដោយប្រើប្រាស់ទឹកអណ្ដូងស្នប់ដែលជារើយៗ ត្រូវរីងស្ងួតយ៉ាងឆាប់រហ័សនៅរដូវប្រាំង ធ្វើឲ្យបន្លែរបស់គាត់មិនអាចលូតលាស់ផ្ដល់ផលបានល្អ។

ក្នុងពេលកំពុងឈរចន្លោះរងស្ពៃ ជីរ និងសណ្ដែកកួរ គាត់បានពោលថា “ឥឡូវនេះខ្ញុំមានកង្វល់អំពីរឿងទឹកដូចមុនទៀតហើយ។ ឥឡូវនេះខ្ញុំគិតតែប្រឹងធ្វើយ៉ាងណាដាំឲ្យបានច្រើនមុខ”។

ជារៀងរាល់ថ្ងៃ គាត់ក្រោកពីសម្រាន្តនៅម៉ោង ៣ព្រឹក ដើម្បីចាប់ផ្ដើមប្រមូលផលបន្លែ និងយកទៅលក់នៅទីផ្សារឲ្យបានមុនថ្ងៃរះ។ គាត់បានទទួលប្រាក់ចំណូលប្រចាំថ្ងៃប្រមាណ ៥ដុល្លាអាមេរិក ដែលជាចំណូលមួយខ្ពស់ជាងចំណូលប្រចាំថ្ងៃរបស់កម្មករកាត់ដេរ។ ប៉ុន្តែគាត់ពុំទាន់ពេញចិត្តនៅឡើយទេ និង បានតាំងចិត្តថានឹងបង្កើនប្រាក់ចំណូលដោយដាំដំណាំឲ្យបានច្រើនមុខថែមទៀត។

គាត់បានរម្លឹកថា “កាលពីឆ្នាំទៅ ខ្ញុំដាំតែស្ពៃ ប៉ុន្តែលក់អត់អស់ ដល់អញ្ចឹងមិនដឹងយកទៅណាមានតែបោះចោល ឬឲ្យជ្រូកស៊ី។ តែឥឡូវខ្ញុំដាំច្រើនមុខ នេះបន្តិច នោះបន្តិច ដើម្បីស្របតាមតម្រូវការនៃទីផ្សារ”។

គម្រោងនេះ - លើកកំពស់ការគ្រប់គ្រងទឹកនិងកសិកម្មដែលធន់នឹងអាកាសធាតុនៅជនបទនៃប្រទេសកម្ពុជា - ឥឡូវនេះស្ថិតក្នុងដំណាក់កាលទីពីរ ក្រោយពីបានទទួលមូលនិធិពីប្រទេសកាណាដា កាលពីចុងឆ្នាំ២០១៣។ គម្រោងនេះគាំទ្រដល់ប្រជាជនក្រីក្រ និងដែលគ្មានដីធ្លីប្រមាណ ៥.៥០០ គ្រួសារ នៅក្នុងឃុំចំនួន ៣២ នៃស្រុកចំនួនបួនក្នុង ខេត្តព្រះវិហារ និងក្រចេះ។ គម្រោងនេះមានសកម្មភាពជាច្រើនមុខ ជាអាទិ៍បច្ចេកទេសពិពិធកម្មមុខដំណាំ និងការគ្រប់គ្រងធនធានទឹកបានប្រសើរជាងមុន។ ក្រៅពីជួយកែលម្អការស្រោចស្រពដំណាំស្រូវ គម្រោងនេះ ក៏បានតម្លើងម៉ាស៊ីនបូមទឹកដែលដើរដោយថាមពលព្រះអាទិត្យផងដែរ ដើម្បីផ្គត់ផ្គង់ទឹកដល់អ្នកភូមិទាំងសម្រាប់ការប្រើប្រាស់តាមគ្រួសារ និងការស្រោចដំណាំក្នុងច្បារផងដែរ។ ពួកគាត់ត្រូវបង់ថ្លៃទឹកក្នុងអត្រាទាបដើម្បីបញ្ចូលក្នុងបេឡាមួយសម្រាប់ថែរក្សាប្រព័ន្ធផ្គត់ផ្គង់ទឹកនេះ។

នៅខេត្តព្រះវិហារ ប្រព័ន្ធចែកចាយទឹកចំនួន ១៦ គ្រឿង ដែលដើរដោយថាមពលព្រះអាទិត្យ ដែលមួយគ្រឿងៗថ្លៃ ៦.៥០០ដុល្លាអាមេរិក ត្រូវបានតម្លើងសម្រាប់ផ្ដល់ទឹកដល់ប្រជាជនចំនួន ២១០ គ្រួសារនៅក្នុងឃុំចំនួន១០។ ប្រជាជនទាំងនោះប្រមាណ ៥០គ្រួសារមានស្ត្រីជាមេគ្រួសារ ដែលបច្ចុប្បន្ននេះអាចយកពេលវេលាពីការស្វែងរកទឹក មកធ្វើការដាំដំណាំដើម្បីរកប្រាក់ចំណូលបន្ថែមសម្រាប់គ្រួសារវិញ។ កូនៗរបស់ពួកគេក៏បានរួចពីការជួយរែកបន្ទុកកិច្ចការក្នុងផ្ទះនេះដែរ ដើម្បីផ្ដោតលើការសិក្សារបស់ពួកគេ។

ការងារប្រចាំថ្ងៃរបស់គាត់ពិតជាច្រើន ប៉ុន្តែ អ្នកស្រី រួន ម៉ាច បានពោលថា ការនឿយហត់នេះមិនអាចបន្ទុចបង្អាក់ការតាំងចិត្តឈានទៅសម្រេចសុបិនរបស់គាត់ដើម្បីកសាង”ជីវិតប្រសើរជាងមុន” បានឡើយ។

គាត់ពោលថា “ខ្ញុំមិននៅចាំឲ្យគេប្រាប់ថាខ្ញុំគួរធ្វើអីឡើយ។ ខ្ញុំនឹងប្រឹងថែមទៀតដើម្បីរកលុយឲ្យបានច្រើនជាងនេះ ហើយមិនមែនដើម្បីតម្រូវចិត្តអ្នកណាទេ គឺដើម្បីតែខ្លួនខ្ញុំនិងគ្រួសារខ្ញុំ”។



PHOTO: UNDP Cambodia

*ប្រព័ន្ធចែកចាយទឹកដើរដោយថាមពលពន្លឺព្រះអាទិត្យ ដែលផ្គត់ផ្គង់ថវិកាដោយប្រទេសកាណាដា ជួយផ្ដល់ទឹកដល់អ្នកភូមិធម្មជាតិសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងដាំបន្លែច្រើនមុខដើម្បីបង្កើនចំណូលក្នុងគ្រួសារ។*

# លោកស្រីគុយ សាមឿន គំរូជោគជ័យមួយក្នុងការធ្វើកសិកម្មចម្រុះ

**ខេត្តព្រះវិហារ** - អ្នកស្រី គុយ សាមឿន ធ្វើការពន្យល់ដល់អ្នកភូមិមួយក្រុមអំពីរបៀបផ្សំថ្នាំសារជាតុសរីរាង្គ ដើម្បីទប់ស្កាត់សត្វចង្រៃពីការបំផ្លាញបន្លែ។ គាត់ពន្យល់បណ្តើរចង្អុលបណ្តើរទៅកាន់ជាតុផ្សំធម្មជាតិជាងដប់មុខ មានជាអាទិ៍ ឫសរុក្ខជាតិ ខ្ទឹមស ស្លឹកគ្រៃ ម្ទេស ខ្ញី និងថ្នាំជក់ ដែលត្រូវបានគេដាក់តម្រៀងគ្នានៅលើគ្រែឈើមួយ ក្រោមដើមខ្នុរមុខផ្ទះរបស់លោកស្រី។

ទៅកាន់អ្នកភូមិដែលកំពុងធ្វើការកត់ត្រាលើកូនសៀវភៅ លោកស្រីគុយ សាមឿន និយាយថា “ពេលវេលាល្អបំផុតសម្រាប់បាញ់ទឹកថ្នាំនេះគឺ ព្រឹកព្រលឹម និងពេលព្រលប់។ នេះជាពេលដែលសីតុណ្ហភាពមិនសូវក្តៅពេក ហើយសត្វល្អិតចង្រៃនានាចូលចិត្តមកប្រមូលផ្តុំនៅលើដំណាំ។ ប៉ុន្តែកុំភ្លេចពាក់ម៉ាស់លើច្រមុះផង”។

នេះជាការជួបជុំគ្នាមួយមានលក្ខណៈជាវគ្គបណ្តុះបណ្តាលអមដោយការអនុវត្តជាក់ស្តែង ដែលអ្នកស្រី គុយ សាមឿន បានបង្រៀនដល់អ្នកភូមិផងរបងជាមួយក្នុងភូមិទឹកក្រហម ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ នេះរបៀបមួយក្នុងការអនុវត្តវិធីកសិកម្មចម្រុះ - ដោយបង្កើនមុខដំណាំ ដាំឈើហូបផ្លែ និងចិញ្ចឹមត្រី និងសត្វ - ដើម្បីបង្កើនប្រាក់ចំណូលប្រចាំគ្រួសារ។ ក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ ស្ត្រីក្នុងវ័យ ៥៨ឆ្នាំរូបនេះដែលជាកសិករគំរូម្នាក់មានជោគជ័យក្នុងការធ្វើកសិកម្មចម្រុះ បានបង្រៀនបច្ចេកទេសបែបនេះដល់កសិករមកពីជិតឆ្ងាយជាច្រើនលើករួចមកហើយ។

លោក ម៉ៅ សាម៉ុល បុរសអាយុ ៧៥ឆ្នាំដែលរស់នៅក្នុងភូមិនេះដែរបានពោលថា “ខ្ញុំមកទីនេះជាញឹកញាប់ដើម្បីសួរគាត់ ព្រោះថាគាត់បានជំនាញប្រសប់ជាងខ្ញុំ។ ខ្ញុំបានប្រើប្រាស់ចំណេះដឹងដែលគាត់បានចែករំលែក ហើយចំណេះដឹងនេះបានធ្វើឲ្យមានភាពខុសគ្នាយ៉ាងច្រើនធៀបនឹងការដាំបន្លែតាមបែបបុរាណពីមុនមក”។



PHOTO: UNDP Cambodia

*ប្តីលោកស្រី គុយ សាមឿន និងចៅប្រុសពីរនាក់កំពុងចាប់ត្រីពីក្នុងស្រះដែលជាផ្នែកមួយនៃការធ្វើកសិកម្មចម្រុះសម្រាប់បង្កើនភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។*

អ្នកស្រី គុយ សាមឿនទទួលបានជំនាញនេះតាមរយៈវគ្គបណ្តុះបណ្តាលនៅក្រោមគម្រោងមួយដែលគាំទ្រដោយ UNDP។ ក្នុងអំឡុងពេលបីឆ្នាំកន្លងមកនេះ គាត់បានធ្វើទស្សនកិច្ចសិក្សាចំនួនពីរលើកទៅប្រទេសថៃ ដើម្បីរៀនអំពីវិធីនានាក្នុងប្រព័ន្ធដាំដំណាំចម្រុះ។ នៅក្នុងការប្រឡងប្រណាំងរបរកសិកម្មទូទាំងប្រទេសកាលពីឆ្នាំ ២០១៣ គាត់បានឈ្នះគូប្រជែងដទៃទៀតពីខេត្ត-ក្រុងចំនួន ២៤ និងបានទទួលរង្វាន់លេខ ១ ដែលមានម៉ាស៊ីនភ្ជួរដីមួយគ្រឿង និងប្រាក់ ៣០០ដុល្លាអាមេរិក ពីរដ្ឋាភិបាល។ ដោយសារជោគជ័យរបស់គាត់គម្រោងបានសាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍មួយនៅលើដីលំណៅដ្ឋានរបស់គាត់ ដើម្បីផ្តល់កន្លែងចែករំលែកចំណេះដឹងដល់ភ្ញៀវមកពីក្នុងភូមិរបស់គាត់ និងពីខេត្តឆ្ងាយៗ។

គម្រោងនេះ - លើកកំពស់ការគ្រប់គ្រងទឹក និងកសិកម្មដែលធន់នឹងអាកាសធាតុតាមជនបទក្នុងប្រទេសកម្ពុជា - ឥឡូវនេះឈានដល់ដំណាក់កាលទី ២ ក្រោយពីបានទទួលមូលនិធិពី កាណាដា នៅចុងឆ្នាំ ២០១៣។ គម្រោងនេះដំណើរការក្រោមកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង មន្ទីរកសិកម្មខេត្តព្រះវិហារ ដើម្បីអនុវត្តសកម្មភាពនានា ដែលរួមទាំងរបៀបកែលម្អបច្ចេកទេសដាំដំណាំ និងការស្រោចស្រពក្នុងគោលដៅកសាងភាពធន់របស់អ្នកភូមិចំពោះការប្រែប្រួលអាកាសធាតុ។



PHOTO: UNDP Cambodia

*អ្នកភូមផងរបងជាមួយរបស់លោកស្រី គុយ សាមឿន មករៀនអំពីវិធីផ្សំថ្នាំធម្មជាតិសម្រាប់សម្លាប់សត្វល្អិតស៊ីដំណាំ។*

# ស៊ុយអែដបន្តផ្តល់ហិរញ្ញវត្ថុសម្រាប់កម្មវិធីប្រែប្រួលអាកាសធាតុ...

*តពីទំព័រទី ១*



PHOTO: UNDP Cambodia

*ស្វាមីនិងភរិយាមួយគូនេះកំពុងដាំត្រាវនៅភូមិក្រាំងសេរី ខេត្តកំពង់ស្ពឺ ដែលនៅទីនោះប្រទេសស៊ុយអែដ បានផ្តល់ថវិកាដល់គម្រោងស្តារអាងទឹកសម្រាប់ផ្គត់ផ្គង់ដល់ការប្រើប្រាស់ប្រចាំថ្ងៃ និងការដាំដំណាំរបស់កសិករនៅទៅនោះ។*

លោកស្រី Anna Maj Hultgård ឯកអគ្គរដ្ឋទូតស៊ុយអែដ និងលោកស្រី Setsuko Yamazaki នាយកយូអិនឌីភី ប្រចាំនៅកម្ពុជា កាលពីថ្ងៃទី ១៤ វិច្ឆិកា បានចុះហត្ថលេខាជាផ្លូវការលើកិច្ចព្រមព្រៀងជំនួយនេះ ដើម្បីបន្តកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ទៅក្នុងដំណាក់កាលទីពីរ ដែលនឹងអនុវត្តរហូតដល់ឆ្នាំ ២០១៩។

នៅក្នុងឱកាសនោះ លោកស្រី Anna Maj Hultgård មានប្រសាសន៍ថា “កំណើនភាពធន់នឹងការប្រែប្រួលអាកាសធាតុ ផលប៉ះពាល់បរិស្ថាន និងគ្រោះមហន្តរាយធម្មជាតិ គឺជាគោលដៅសំខាន់មួយនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់ស៊ុយអែដជាមួយកម្ពុជា សម្រាប់អំឡុងឆ្នាំ ២០១៤-២០១៨។ ដូច្នេះ យើងមានមោទនភាពប្រកាសជាផ្លូវការនៅក្នុងថ្ងៃនេះនូវការបន្តគាំទ្ររបស់យើងដល់កម្មវិធី CCCA ដែលតាមរយៈនេះ យើងរួមជាមួយយូអិនឌីភី និងប្រតិភូសហភាពអឺរ៉ុបនឹងអាចជួយប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនដើម្បីពង្រឹងប្រព័ន្ធ និងសមត្ថភាពរបស់ជាតិសម្រាប់អនុវត្ត និងសម្របសម្រួលបានប្រសើរជាងមុននូវវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុទាំងនៅថ្នាក់កណ្តាល និងនៅថ្នាក់មូលដ្ឋាន។”

ជំនួយឥតសំណងថ្មីនេះ គឺជាជំនួយលើកទីពីររបស់ស៊ុយអែដ ដែលបានផ្តល់វិភាគទានច្រើនជាង ៤,៤លានដុល្លាអាមេរិកដល់កម្មវិធី CCCA នៅក្នុងដំណាក់កាលទីមួយ ឆ្នាំ ២០១០-២០១៤។

ការសិក្សាថ្មីៗនេះបានរកឃើញដូចគ្នាថា កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសនានា ដែលងាយរងគ្រោះបំផុត បណ្តាលពីការប្រែប្រួលអាកាសធាតុ ដោយសារប្រទេសនេះពឹងផ្អែកជាខ្លាំងមកលើកសិកម្ម មានប្រជាជនច្រើនរស់នៅក្នុងតំបន់ទំនាប និងសមត្ថភាពទន់ខ្សោយក្នុងការទប់ទល់នឹងព្រឹត្តិការណ៍ធាតុអាកាសដែលមិនអាចព្យាករណ៍បាន និងធ្ងន់ធ្ងរ ដូចជា គ្រោះរាំងស្ងួត និងទឹកជំនន់។

កម្មវិធី CCCA ត្រូវបានបង្កើតឡើងនៅ ខែកុម្ភៈ ឆ្នាំ ២០១០ ជាកម្មវិធីពហុម្ចាស់ជំនួយ ដើម្បីធ្វើជាច្រកឯកភាពគ្នាមួយសម្រាប់ដៃគូអភិវឌ្ឍន៍ផ្តល់ធនធានសម្រាប់កិច្ចផ្តួចផ្តើមប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ម្ចាស់ជំនួយនានាដល់កម្មវិធីនេះនៅដំណាក់កាលទីមួយ រួមមាន ស៊ុយអែដ សហភាពអឺរ៉ុប ដាណឺម៉ាក់ និង យូអិនឌីភី។ កម្មវិធីនេះបានគាំទ្រដល់ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការអនុវត្តគម្រោងបង្ហាញចំនួន ២០ ដែលមានគោលដៅសាកល្បងវិធានការបន្សាំ ដើម្បីបង្កើនភាពធន់នៃសហគមន៍ជនបទដែលប្រឈមខ្លាំងបំផុតចំពោះហានិភ័យនៃការប្រែប្រួលអាកាសធាតុ។

នៅថ្នាក់ជាតិ កម្មវិធី CCCA គាំទ្រដល់គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ក្នុងការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងប្រព័ន្ធនានានិងថវិការបស់រដ្ឋាភិបាល។ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) ត្រូវបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការកាលពីឆ្នាំទៅ ជាក្របខ័ណ្ឌយុទ្ធសាស្ត្រអាកាសធាតុដំបូងបង្អស់របស់កម្ពុជា។ ផែនការនេះចែងអំពីចក្ខុវិស័យរបស់រដ្ឋាភិបាល ក្នុងការលើកកំពស់ការអភិវឌ្ឍដែលបំភាយកាបូនទាប និងធន់ចំពោះអាកាសធាតុសម្រាប់រយៈពេល ១០ឆ្នាំ ខាងមុខ។ កម្មវិធី CCCA ដំណាក់កាលទីពីរនឹងបន្តសមិទ្ធផលកន្លងមកដើម្បីពង្រឹងបន្ថែមទៀតនូវយន្តការស្ថាប័ន និងប្រព័ន្ធអភិបាលកិច្ច ជម្រុញភាពជាដៃគូក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់និងបង្កើនសមត្ថភាពមនុស្សនិងបច្ចេកវិទ្យា សម្រាប់អនុវត្តសកម្មភាពជាអាទិភាពដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រនេះ។

លោកស្រី Setsuko Yamazaki នាយកការិយាល័យយូអិនឌីភី មានប្រសាសន៍ថា “ដើម្បីសម្រេចគោលបំណងទាំងនេះ កម្មវិធី CCCA នឹងបន្តផ្តល់ការគាំទ្រខាងគោលនយោបាយ និងការអនុវត្តបង្ហាញសកម្មភាពច្នៃប្រឌិតថ្មីតាមរយៈជំនួយឥតសំណង។ ក្នុងន័យនេះ យើងនឹងធ្វើការជាមួយរដ្ឋាភិបាលស៊ុយអែដ ឆ្ពោះទៅសម្រេចគោលបំណងរួមរបស់យើង គឺការកាត់បន្ថយភាពក្រីក្រ និងពង្រឹងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងបរិស្ថានដោយចីរភាពដោយផ្អែកលើសមត្ថភាពរបស់ប្រជាជនផ្ទាល់ ក្នុងការដឹកនាំការអភិវឌ្ឍ។ យើងសូមថ្លែងអំណរគុណផងដែរចំពោះប្រជាជនស៊ុយអែដ ដែលបានផ្តល់ វិភាគទានដ៏សប្បុរសទាំងនេះ ទាំងពីអតីតកាល និងបច្ចុប្បន្ន”។

លោកស្រី Yamazaki បានបន្ថែមថា “ការយកចិត្តទុកដាក់របស់យើងនឹងនៅតែផ្តោតលើការសាងភាពធន់របស់ប្រជាពលរដ្ឋក្រីក្រជាងគេ និងដែលងាយរងគ្រោះបំផុត ដើម្បីពួកគេអាចចាក់ផុតពីភាពក្រីក្រ។ ក្នុងន័យនេះ យូអិនឌីភី នឹងបន្តធ្វើការជិតស្និទ្ធជាមួយស៊ុយអែដ ដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដែលជាផ្នែកមួយនៃសេចក្តីប្រាថ្នារបស់ខ្លួនឆ្ពោះទៅសម្រេចឲ្យបានការអភិវឌ្ឍដោយចីរភាពសម្រាប់អនាគតយូរអង្វែង”។

UNDP
Empowered lives.
Resilient nations.

អគារលេខ ៥៣ វិថី ប៉ាស្ទ័រ សង្កាត់ បឹងកេងកង១
ប្រអប់សំបុត្រលេខ ៨៧៧ ក្រុងភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ +855 (0) 23 216 167
ទូរសារ ៖ +855 (0) 23 216 257
អ៊ីម៉ែល ៖ registry.kh@undp.org
www.kh.undp.org
www.facebook.com/UNDPCambodia
www.twitter.com/UNDPCambodia